UNITED NATIONS
OFFICE OF THE HIGH COMMISSIONER
FOR HUMAN RIGHTS IN CAMBODIA

NATIONS UNIES
BUREAU DU HAUT COMMISSAIRE
AUX DROITS DE L'HOMME AU CAMBODGE

អង្គការសហប្រជាជាតិ
ការិយាល័យនៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា

OHCHR

# លោក គ្រីស្តូហ្វ ប៉េស្ស៊ូ តំណាងឧត្តមស្នងការសិទ្ធិមនុស្សប្រចាំកម្ពុជា ថ្លែងសន្ទរកថាបើក វេទិកាថ្នាក់ជាតិស្តីពីជនជាតិដើមភាគតិច ដែលប្រារព្ធធ្វើនៅទីក្រុងភ្នំពេញ ពីថ្ងៃទី២៧ ដល់ ២៨ ខែតុលា ឆ្នាំ២០០៨

លោក លោកស្រីជាទីគោរពរាប់អាន,

ខ្ញុំមានក្តីសោមនស្សរីករាយដែលបានទទួលការអញ្ជើញចូលរួមថ្លែងសន្ទរកថាបើកវេទិកាថ្នាក់ជាតិនៅថ្ងៃនេះ ។ លោក លោកស្រីភាគច្រើនបានធ្វើដំណើរមកពីទីឆ្ងាយ ដូច្នេះ ខ្ញុំសូមសំដែងកិច្ចស្វាគមន៍យ៉ាងកក់ក្តៅ ហើយសង្ឃឹមថាយើងនឹងមានការជួបប្រជុំ និងការពិភាក្សាគ្នាយ៉ាងផុលផុស ។

រហូតមកទល់ពេលនេះគឺមានរយៈពេលមួយឆ្នាំហើយ ចាប់ពីមានការអនុម័តសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិជនជាតិដើមភាគតិច ។ នេះគឺជាជំហានមួយដ៏សំខាន់ក្នុងការទទួលស្គាល់ជាអន្តរជាតិអំពីសិទ្ធិជាក់លាក់របស់សហគមន៍ជនជាតិដើមភាគតិច ។ សេចក្តីប្រកាសនេះ ត្រូវបានប្រទេសចំនួន១៤៣ ដោយរួមទាំងប្រទេសកម្ពុជាផងបានអនុម័តយល់ព្រម ។ សេចក្តីប្រកាសនេះតម្រូវឱ្យរដ្ឋាភិបាលទទួលខុសត្រូវក្នុងការទាញយកបំណងប្រាថ្នាពីឯកសារនោះ ដើម្បីកំណត់ និងអនុវត្តគោលនយោបាយជាតិមួយដែលទទួលស្គាល់ លើកស្ទួយ និងការពារសិទ្ធិជនជាតិដើមភាគតិច ។

ការរីកចំរើនជាវិជ្ជមានមួយក្នុងឆ្នាំកន្លងទៅនេះ គឺសហគមន៍ជនជាតិដើមភាគតិចមានសមត្ថភាពយល់ដឹងច្រើនថែមទៀតអំពីសិទ្ធិរបស់ខ្លួនដូចជា ការធ្វើឱ្យគេដឹងឮអំពីមតិយោបល់របស់ខ្លួន និងការសំដែងអំពីកង្វល់នៅពេលមានការរំលោភសិទ្ធិពួកគាត់ (កង្វល់កើតមានជាញឹកញយបំផុតនោះគឺ ការរំលោភយកដីធ្លី និងធនធានរបស់គាត់ពីសំណាក់បុគ្គលដែលមានអំណាច) ដែលជារឿយៗមានការសមគំនិតពីអាជ្ញាធរសាធារណៈមួយចំនួន ។ ពួក

គាត់បានចាត់វិធានការផ្សេងៗដើម្បីជួបពិភាក្សាអំពីទុក្ខព្រួយ ហើយប្រមូលគ្នាធ្វើដំណើរទៅកាន់ទីរួមខេត្ត និងរាជធានីភ្នំពេញដើម្បីសំដែងអំពីកង្វល់របស់ខ្លួន។

ការអាចធ្វើដំណើរ ការអាចជួបអ្នកដទៃ ការអាចពិភាក្សាអំពីបញ្ហាផ្សេងៗដែលកើតមានក្នុងជីវិតរស់នៅរបស់អ្នកដោយគ្មានការភ័យខ្លាច និងគ្មានការរិតត្បិត ការអាចសំដែងអំពីកង្វល់របស់អ្នកប្រាប់អ្នកដទៃ ការអាចរៀបចំពិធីផ្សេងៗ ការអាចជួបនិងនិយាយប្រាប់អាជ្ញាធរអំពីកង្វល់របស់ខ្លួន ទាំងអស់នេះគឺជាសិទ្ធិសំខាន់បំផុតសំរាប់អ្នកទាំងអស់គ្នាដើម្បីអាចរៀបចំជីវិតរស់នៅរបស់ខ្លួន និងដើម្បីស្ថាបនាពិភពលោកមួយដែលអ្នកទាំងអស់គ្នាតែងតែប្រាថ្នាចង់បាន។ ទាំងអស់នេះ គឺជាសិទ្ធិសារវ័ន្តរបស់មនុស្សគ្រប់រូបនៅកម្ពុជា។

ខ្ញុំនិយាយអំពីសិទ្ធិទាំងនេះ ពីព្រោះខ្ញុំដឹងថា ជានិច្ចជាកាល សិទ្ធិទាំងនេះមិនត្រូវបានគេគោរពនោះទេ - ការសំដែងមតិជាសាធារណៈ តាមរយៈការដើរជាក្បួនដោយសន្តិភាព ការធ្វើបាតុកម្ម និងការប្រមូលផ្តុំគ្នាស្ទើរតែលែងមានហើយនៅកម្ពុជា។ ខ្ញុំដឹងអំពីករណីមួយចំនួន ដែលជនជាតិដើមភាគតិចត្រូវគេបំភិតបំភ័យ ហើយជួនកាលត្រូវអាជ្ញាធរមូលដ្ឋានរារាំងមិនឱ្យធ្វើដំណើរចេញពីភូមិ ឬពីខេត្តរបស់ខ្លួន ទៅជួបសហគមន៍ដទៃទៀតដែលរងផលប៉ះពាល់ដោយការដកហូតយកដីធ្លី ទៅចូលរួមក្នុងវគ្គបណ្តុះបណ្តាលផ្សព្វផ្សាយការយល់ដឹងអំពីសិទ្ធិរបស់ពួកគាត់ ឬទៅចូលរួមប្រជុំនៅរាជធានីភ្នំពេញ។ ពិតណាស់ ការរិតត្បិតទាំងនេះគឺជាទង្វើខុសច្បាប់ និងជាការរំលោភបំពាន។

ជួនកាល អាជ្ញាធរចោទប្រកាន់បុគ្គលមួយចំនួននៅក្នុងសហគមន៍ទាំងនេះ និងអង្គការក្រៅរដ្ឋាភិបាលដែលធ្វើការជាមួយជនជាតិដើមភាគតិចពីបទ " ការញុះញង់ " ដើម្បីបំភិតបំភ័យពួកគេ តាមរយៈការគំរាមចាត់វិធានការតាមផ្លូវច្បាប់។ ពាក្យថា " ការញុះញុះ " នេះគឺគេនិយាយសំដៅដល់ការនាំឱ្យមានការតវ៉ាប្រឆាំងនឹងអាជ្ញាធរ។ ប៉ុន្តែសួរថា តើប្រជាជនទាំងនោះគាត់ធ្វើអ្វី? ពួកគាត់អនុវត្តសិទ្ធិរបស់គាត់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ក្នុងច្បាប់ភូមិបាលឆ្នាំ២០០១ ក្នុងអនុក្រឹត្យនានាដែលពាក់ព័ន្ធ។ ការអនុវត្តន៍សិទ្ធិដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ( ដោយសន្តិវិធី) មិនអាចជាបទល្មើសបានឡើយ ពុំនោះទេ រដ្ឋធម្មនុញ្ញជាអ្នកបង្កើតឱ្យមានការញុះញង់ ....

ការិយាល័យយើងខ្ញុំបានធ្វើការងារនេះរយៈពេលជាច្រើនឆ្នាំមកហើយៗ និងបន្តធ្វើការងារនេះយ៉ាងជិតស្និទ្ធជាមួយសហគមន៍ដែលរងផលប៉ះពាល់ដោយការដណ្តើមយកដីធ្លី ( ការដណ្តើមយកដីធ្លីសំដៅដល់ការលួចប្លន់ជាបទល្មើសមួយដែលមានចែងក្នុងច្បាប់) ជាមួយនឹងអង្គការក្រៅរដ្ឋាភិបាល អាជ្ញាធរមូលដ្ឋាន និងអាជ្ញាធរជាតិក្នុងការស្វែងរកដំណោះស្រាយសមស្រប ផ្អែកលើរដ្ឋធម្មនុញ្ញ ច្បាប់ភូមិបាល និងអនុក្រឹត្យនានាដែលពាក់ព័ន្ធ។

បញ្ហាជាក់ស្តែងមួយដែលជនជាតិដើមភាគតិចកំពុងជួបប្រទះនោះគឺ ការទទួលស្គាល់សិទ្ធិរបស់ខ្លួនលើដីព្រៃពេណី។ អនុក្រឹត្យស្តីពីការចុះបញ្ជីដីជនជាតិដើមភាគតិចកំពុងរៀបចំព្រាងនៅឡើយ។ ទន្ទឹមនឹងការដែលសហគមន៍ផ្តល់មតិលើសេចក្តីព្រាងអនុក្រឹត្យ ជាជំហានមួយដ៏សំខាន់នោះ គេនៅមិនទាន់ដឹងច្បាស់ថាតើសេចក្តីផ្តល់មតិរបស់គាត់ត្រូវបានគេទទួលយកត្រឹមកំរិតណា ដោយសារថា ពួកគាត់មិនទាន់ទទួលបានសេចក្តីព្រាងដែលពិនិត្យ

ឡើងវិញនោះនៅឡើយ ។ ទោះជាយ៉ាងណាក៏ដោយ រដ្ឋាភិបាលបានយល់ព្រមឱ្យមានការពិគ្រោះយោបល់បន្ថែមទៀត មុននឹងសំរេចយកអត្ថបទចុងក្រោយ ។

ក្នុងពេលនេះ គេត្រូវការឱ្យមានវិធានការបង្ការបណ្តោះអាសន្ន ដើម្បីការពារដីធ្លីទាំងនោះពីការទន្ទ្រានយក ។ យើងមានកង្វល់ថា ប្រសិនជាការព្រាង និងការអនុវត្តន៏អនុក្រឹត្យនេះអូសបន្លាយពេលវេលាវែងពេក នោះសហគមន៍ជនជាតិដើមភាគតិចនឹងបន្តបាត់បង់ដីធ្លីរបស់ខ្លួន ដោយសារ សម្បទានដីសេដ្ឋកិច្ច ឬឈ្មួញឯកជនដែលជាឧបសគ្គដល់សហគមន៍ជនជាតិដើមភាគតិច ។ យើងនឹងបន្តធ្វើការជាមួយសហគមន៍ អង្គការក្រៅរដ្ឋាភិបាល ប្រទេសអ្នកផ្តល់ជំនួយនានា និងរដ្ឋាភិបាល ដើម្បីធានាឱ្យវិធានការបង្ការនេះអនុវត្តមានប្រសិទ្ធភាព ។

នៅទីបញ្ចប់ ខ្ញុំសូមនិយាយតិចតួចអំពីការអភិវឌ្ឍន៍ ។គ្មាននរណាម្នាក់ប្រឆាំងនឹងការអភិវឌ្ឍន៍នោះទេៈ មនុស្សគ្រប់រូបមានបំណងប្រាថ្នាចង់រស់ក្នុងបរិយាកាសមួយដែលគាត់អាចអភិវឌ្ឍន៍ដល់កំរិតដែលគាត់អាចធ្វើបាន ដោយគោរពទូវអត្តសញ្ញាណ និងភាពផ្សេងគ្នា ។ សំរាប់ខ្ញុំ ការអភិវឌ្ឍន៍គឺមានន័យដូច្នេះ គឺការគិតគូរអំពីមនុស្ស មនុស្សទាំងអស់ ជាស្នូលនៃដំណើរការអភិវឌ្ឍន៍ ។ ប៉ុន្តែបរិស្ថានក៏រួមចំណែកក្នុងដំណាក់កាលនេះដែរ ធ្វើដូច្នេះគេអាចគ្រប់គ្រងធនធានធម្មជាតិបានល្អ និងប្រកបដោយចិរភាពសំរាប់ជាប្រយោជន៍ដល់មនុស្សបច្ចុប្បន្ន និងមនុស្សជំនាន់ក្រោយ ។ អានាគតកូនចៅយើងគឺពឹងផ្អែកទាំងស្រុងលើលទ្ធភាពរបស់យើងក្នុងការធានាអានាគតនៃធនធានធម្មជាតិដូចជា ដីធ្លី ទឹក ទន្លេ បឹង រុក្ខជាតិ ព្រៃឈើ សត្វ និងយើងទាំងអស់គ្នា យើងកំពុងស្ថិតនៅលើទូកមួយជាមួយគ្នា យើងមានជោគវាសនាដូចគ្នា យើងរស់នៅលើភពមួយជាមួយគ្នា ។ ខ្ញុំដឹងថាលោក លោកស្រីភាគច្រើនយល់ដូច្នេះ ហើយសង្ឃឹមថាកូនចៅលោកអ្នកនឹងបានស្គាល់ព្រៃឈើ និងដីធ្លី ដូចជាលោកអ្នកដែរ ។

នេះជាន័យនៃការអភិវឌ្ឍន៍មនុស្ស និងប្រកបដោយចិរភាពផងដែរ ។ ហើយក្នុងនោះ គោលការណ៍សំខាន់គឺត្រង់ថាវាស្រេចទៅលើសហគមន៍ពាក់ព័ន្ធជាអ្នកសំរេចអំពីទ្រង់ទ្រាយ និងជំហាននៃការអភិវឌ្ឍន៍ដែលពួកគាត់ចង់បានសំរាប់សហគមន៍ ភូមិ និងគ្រួសារគាត់ - និងការធ្វើការរួមគ្នាដើម្បីបង្កើតវាឡើង ។ គ្មានអភិវឌ្ឍន៍ណាមួយដែលអ្នកក្រៅជាអ្នកត្រូវកំណត់ឱ្យធ្វើ ដោយមិនមានការពិគ្រោះយោបល់ត្រឹមត្រូវនោះឡើយ ។ ការអភិវឌ្ឍន៍ណាមួយដែលមិនគិតគូរអំពីការពិតជាក់ស្តែង និងបំណងប្រាថ្នារបស់ប្រជាពលរដ្ឋ ហើយសំរាប់តែបំរើឱ្យអ្វីដែលគេហៅថាសេដ្ឋកិច្ចនោះ ការអភិវឌ្ឍន៍បែបនោះ គេមិនហៅថាមានមនុស្សធម៌ឡើយ ។ ការអភិវឌ្ឍន៍គឺជាកង្វល់របស់មនុស្សគ្រប់រូប ពីព្រោះវាបង្ហាញអំពីបែបផែននៃពិភពលោកមួយដែលយើងទាំងអស់គ្នាចង់រស់នៅ ។ នេះជាពិភពលោករបស់យើងរាល់គ្នា វាមិនមែនជាពិភពលោករបស់អ្នកណាម្នាក់នោះឡើយ ។

ខ្ញុំជូនពរលោក លោកស្រីទាំងអស់គ្នា សូមទទួលបានជោគជ័យក្នុងវេទិការនេះ ហើយខ្ញុំសង្ឃឹមថាការចែករំលែកចំណេះដឹង និងបទពិសោធគ្នាទៅវិញទៅមកនៅក្នុងពេលពីរថ្ងៃបន្ទាប់ពីនេះនឹងឈានទៅការពារ និងលើកស្ទួយសិទ្ធិមនុស្សគ្រប់រូបខ្លាំងក្លាឡើងថែមទៀតនៅកម្ពុជា ។ ខ្ញុំសូមធ្វើការអះអាងថា ការិយាល័យឧត្តមស្នងការ

អ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សនឹងបន្តផ្តល់ការគាំទ្រ និងការជួយឧបត្ថម្ភដល់អស់លោក លោកស្រី នៅពេលមានការទាមទារសិទ្ធិរបស់ខ្លួន។

សូមអរគុណ !